# ក្រមានិងជីវភាពប្រជាជនខ្មែរ

ដោយ : **លោកស្រីបណ្ឌិត ជា វណ្ណី**
ប្រធាននាយកដ្ឋានធម្មសាស្ត្រ ចរិយាសាស្ត្រនិងយេនឌ័រ
វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
រាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

ក្រមា គឺជាឧបករណ៍ប្រើប្រាស់បែបប្រពៃណីខ្មែរជាយូរលង់ណាស់មកហើយ គឺប្រហែលជាមានអាយុកាលតាំងពីសម័យមុនអង្គរ(នគរភ្នំ) ចន្លោះសតវត្សទី១និងទី៥នៃគ.ស.។ បើតាមវចនានុក្រម សម្រេចព្រះសង្ឃរាជ **ជួន ណាត** «ក្រមា» នាមសព្ទ សំពត់ត្បាញដោយអំបោះមានក្រឡាខ្វែង សម្រាប់ផ្លាស់ងូតទឹក។[១] បើយោងតាមបញ្ជីសារពើភណ្ឌមរតកវប្បធម៌អរូបីកម្ពុជា ដែលចេញផ្សាយកាលពីឆ្នាំ២០១៩ «ក្រមា» គឺជាពាក្យដែលខ្មែរខ្ចីពីភាសារបស់ពែរ្ស(Persian) ដែលប្រហែលជាចូលមកខ្មែរក្រោយសតវត្សទី១៤។ អ្នកនិយមប្រើពាក្យ «ក្រមា» ភាគច្រើនជាអ្នកនៅទីក្រុង ឬទីប្រជុំជន រីឯអ្នកជនបទនិយមប្រើពាក្យកន្សែងដាង ហើយជួនកាលទៀតអ្នកស្រុកហៅថា «ឈ្នួត» ឬ «សំពត់ដណ្តប់» ដោយអាស្រ័យទៅតាមតំបន់។[២]

ក្រមាខ្មែរត្រូវបានគេប្រើប្រាស់ច្រើនបែបយ៉ាងដូចជា គេយកក្រមាមកបង់កទុកសម្រាប់ជូតញើសនិងប្រើប្រាស់តាមការចាំបាច់ផ្សេងៗ។ គេយកក្រមាធ្វើជាកន្សែងពានាពេលទៅវត្តអារាម។ គេយកក្រមាមករុំនៅលើក្បាលដើម្បីជាម្ចប់ជំនួសមួកសម្រាប់ការពារកំដៅថ្ងៃពេលធ្វើស្រែចម្ការឬទៅណាមកណា។ គេយកក្រមាមកធ្វាយជារង្វើលសម្រាប់ទូលក្អមទឹក ទូលល្អី កញ្ជើរ ឱស ក៏ដូចជាអ្វីផ្សេងៗទៀត។ គេយកក្រមាមកស្លៀកជំនួសខោ អាវ សំពត់ ចងជាអៀម ឬធ្វើជាភួយដណ្តប់។ គេយកក្រមាមកចងធ្វើជាអង្រឹងសម្រាប់ឱ្យកុមារគេង ក៏ដូចជាអាច

[១] ជួន ណាត វចនានុក្រមខ្មែរ។

[២] https://thmeythmey.com/detail/142597 ៧ ធ្នូ ២០២៤

បត់ជាពាងកូនតុក្កាសម្រាប់ក្មេងតូចៗលេង។ គេយកក្រមាមកចងធ្វើថ្នក់សម្រាប់ផ្ទុកអ្វីៗ ជំនួសស្បោងឬថង់។ គេយកក្រមាធ្វើជាចំណងចងរបស់ផ្សេងៗ។ គេយកក្រមាធ្វើជាកម្រាលតុ ឬបត់ជាជាបូរជាផ្កា ជាផ្ទិតសម្រាប់តាំងលម្អតាមគេហដ្ឋាន វត្តអារាម តាមក្រសួង តាមមន្ទីរ និងតាមភោជនីយដ្ឋាននានា។ គេយកក្រមាមកចងក្របួចច្រោះម្សៅអង្ករដែលកិនរួចសម្រាប់យកទៅធ្វើនំ ឬគេយកក្រមាមកព័ទ្ធហុំគ្របឆ្នាំងដែលហើបឱ្យហប់កំដៅល្អ។ គេយកក្រមាមកធ្វើជាឧបករណ៍ក្នុងល្បែងប្រជាប្រិយ ដូចជាល្បែងឈូង ល្បែងលាក់កន្សែង ល្បែងចាប់កូនខ្លែង ល្បែងចងមុខពាវបង្កងល្បែងវាយក្អមល្បែងទាញព្រ័ត្រ(នៅពេលមិនមានខ្សែព្រ័ត្រ)។ គេយកក្រមាមកប្រើធ្វើជាឃ្នៀបគៀប ក៏ដូចជារុំជុំវិញចង្កេះ ក្បាល និងកណ្ដាប់ដៃនៃអ្នកប្រយុទ្ធល្បុក្កតោ។ គេអាចយកក្រមាមកប្រើជាផ្នែកខ្លះនៃពិធីមួយចំនួនដូចជាពិធីបុណ្យ និងមង្គលការផងដែរ ដូចជារុំផ្កាស្លា រុំថង់រង រុំបាយព្រលឹងរុំបាយស្រី ធ្វើជាទ្រនឹបគ្រូ ឬរណ្ដាប់ព្រះពិស្ណុការក្នុងកិច្ចពិធីផ្សេងៗ។ គេយកក្រមាសូត្រជារបស់ប្រចាំចិត្តឬចំណងដៃគូសង្សារ គូករិយាស្វាមីឬកូនប្រសាផងដែរដោយប្រជាជនខ្លះគេជឿថាការប្រើប្រាស់ក្រមាសូត្រជួយលើកពាសី និងអាចការពារខ្លួនពីការបៀតបៀននានាផង និងជាពិសេសនាពេលបច្ចុប្បន្ននេះ ក្រមាត្រូវបានលើកតម្កើងបន្ថែមទៀតដោយនារីខ្មែរមួយចំនួនបានយកមករចនាជាម៉ូតសម្លៀកបំពាក់ ច្នៃជាកាបូបយួរ តាមបែបប្រពៃណីយ៉ាងស្រស់ស្អាត ថែមទៀតផង។

ដូច្នេះសរុបមកក្នុងសង្គមខ្មែរ ក្រមាមានប្រយោជន៍យ៉ាងច្រើនក្នុងជីវភាពប្រចាំថ្ងៃ ដោយប្រជាជនខ្មែរប្រើប្រាស់តាំងពីកើតរហូតដល់ស្លាប់ ដូចជាយកទៅរុំ ដណ្ដប់ ចងធ្វើអង្រឹង ធ្វើជាកម្រាល ធ្វើជាសម្លៀកបំពាក់ ជូតក្បាល ទទូរ ពាទា ជូតញើសឬជូតខ្លួន ចងឬរំបួស បក់ឱ្យរហើយ បក់រុយ ឬមូស ផ្លាស់ផ្លូតទឹក, ធ្វើជាចំណងឬចងប្រទាក់គ្នា ធ្វើពួរ ចងធ្វើថ្នក់ដាក់របស់របរផ្សេងៗ។ល។ និង។ល។



ដោយសារតែក្រមាត្រូវបានប្រជាជនខ្មែរប្រើប្រាស់បានស្ទើរតែគ្រប់បែបយ៉ាង

យ៉ាងដូច្នេះហើយ ទើបក្រមាខ្មែរបានក្លាយទៅជាអត្តសញ្ញាណមួយដែលធ្វើឱ្យជនជាតិខ្មែរមានលក្ខណៈខុសប្លែកពីជនជាតិនានា ជាពិសេសគឺអ្នកជិតខាងយើង មានដូចជា ថៃ វៀតណាម និងឡាវជាដើម ពោលគឺប្រជាជនកម្ពុជាមានទម្លាប់ប្រើក្រមាតែម្តង ហើយដោយសារតែការមើលឃើញពីសារប្រយោជន៍នៃ"ក្រមា" ដូច្នេះហើយ ទើបរាជរដ្ឋាភិបាលកម្ពុជាបានដាក់បញ្ចូលក្រមាបានដោយជោគជ័យក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ កាលពីយប់ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ ២០២៤ តាមរយៈសេចក្តីសម្រេច 19.COM 7.b.27 នៅទីក្រុង**អាសង់ស្យុង** (Asunción) **សាធារណរដ្ឋប៉ារ៉ាហ្គាយ** (Republic of Paraguay) ក្នុងកិច្ចប្រជុំលើកទី១៩ នៃគណៈកម្មាធិការអន្តររដ្ឋាភិបាល ដើម្បីការពារបេតិកភណ្ឌវប្បធម៌អរូបីរបស់អង្គការយូណេស្កូ ដែលនេះគឺជាសមិទ្ធផលដ៏ត្រចះត្រចង់មួយរបស់រាជរដ្ឋាភិបាល ក្នុងកិច្ចការអភិរក្សថែរក្សាការពារមរតកវប្បធម៌ជាតិ និងផ្សព្វផ្សាយវប្បធម៌ខ្មែរទាំងក្នុងប្រទេស និងលើឆាកអន្តរជាតិ។

### . ហេតុអ្វីក្រមានៅតែបន្តមានវត្តមានដោយមិនអាចកាត់ផ្តាច់បាននៅក្នុងជីវភាពខ្មែរ?

ក្រមានៅតែបន្តមានវត្តមានដោយមិនអាចកាត់ផ្តាច់បាននៅក្នុងជីវភាពខ្មែរ ព្រោះក្រមាមានសារៈសំខាន់ណាស់ក្នុងជីវភាពរស់នៅក្នុងសង្គមខ្មែរ។ ប្រជាជនខ្មែរនៅជនបទតែងតែប្រើប្រាស់ក្រមាជាប្រចាំ គឺតាំងពីថ្ងៃកើតរហូតដល់ថ្ងៃស្លាប់ ដូចជា ចងជាអង្រឹង កម្រាល ស្លៀកដណ្តប់ ជូតក្បាល ទទូ ជូតញើសឬខ្លួនប្រាណ បង់ក ធ្វើចំណង ធ្វើថ្នក់ឬដង់ ឬអ្វីផ្សេងៗតាមសេចក្តីត្រូវការ។

ក្រមា មានកស្តុតាងជាច្រើនដូចជាតាមរយៈចម្លាក់ គំនូរ និងក្នុងអក្សរសិល្ប៍ជាដើម។ កស្តុតាងនៅប្រាសាទបន្ទាយឆ្មារ ខេត្តបន្ទាយមានជ័យ ចម្លាក់នៅប្រាសាទបាយ័ន តំបន់អង្គរខេត្តសៀមរាប ដែលអ្នកស្រាវជ្រាវមួយចំនួនយល់ថា ជាការប្រើប្រាស់ក្រមាប្រចាំថ្ងៃដែលជាងចម្លាក់នាសម័យកាលនោះយកមកឆ្លាក់។ កស្តុតាងគំនូរនៅថែវវិហារព្រះកែវមរកត នៅក្នុងព្រះបរមរាជវាំង វត្តកំពង់ត្រឡាចលើ ខេត្តកំពង់ឆ្នាំង វិហារវត្តព្រះស៊ីសុវត្ថិរតនារាមខេត្តកណ្តាល វិហារវត្តរាជបូព៌ ខេត្តសៀមរាប និងគំនូរលើកុដិនៃ

វត្តព្រៃកសំពៅង ក្រុងតាខ្មៅ ខេត្តកណ្ដាល ជាដើម។ ម្យ៉ាងវិញទៀតយើងឃើញមានកស្តុតាងតាមរយៈសំណេរផ្សេងៗមានដូចជា **ច្បាប់ស្រី**របស់**ម៉ឺនមៃ** នាសម័យកណ្ដាល **ច្បាប់ល្បើកថ្មី**របស់**ក្រមង៉ុយ** ឆ្នាំ១៩២២ ចម្រៀងនិងភ្លេង កន្សែងក្រហម កន្សែងសូត្រ កន្សែងបង់ក បទឱផ្ទៃស្រុកខ្មែរ និងក្នុងចម្រៀងជាច្រើនទៀត។

ក្រៅពីនេះ ក្រមាផ្សារភ្ជាប់នឹងជំនឿប្រពៃណី ទំនៀមទម្លាប់របស់ខ្មែរតាំងពីបុរាណកាលមក។ ជាក់ស្ដែងនៅតំបន់**សំបូរព្រៃគុក ខេត្តកំពង់ធំ** អ្នកស្រុកបានយកក្រមាទៅក្រាលក្នុងពិធី**ឡើងអ្នកតា** ដែលជានិមិត្តរូបនៃស្រែ។ ពិធី**ផ្ទុងក្រឡាន** នៅខេត្ត**សៀមរាប** យកក្រឡានដែលធ្វើពីអង្ករស្រូវថ្មីយកទៅគរ ហើយនិមន្តលោកមកទស់[៣] យកក្រឡានក្នុងពិធីនោះ គេយកក្រមាក្រាលឱ្យព្រះសង្ឃនិមន្តទស់ ដើម្បីជាអានិសង្ស។ នៅតាមខេត្តមួយចំនួនអ្ន កស្រុកយកក្រមាទៅគ្របលើមឈូស ហើយកន្ទែងខ្លះគេយកទៅគ្របសពនៅពេលបូជាសព យកក្រាលកញ្ច្រែងមុននឹងរើសធាតុដាក់ និងពេលគេធ្វើកិច្ចហៅព្រលឹង គេយកក្រមាទៅគ្រប។ រីឯនៅតំបន់ខ្លះទៀត គេយកក្រមាទៅដក់ធាតុក៏ដូចជាកិច្ចមួយចុងក្រោយគេហៅ បំពេធាតុ គឺគេយកក្រមាចងធ្វើដូចអង្រឹង រួចយោលបំពេរ ជាដើម។

សូមបញ្ជាក់ថា ក្រមាខ្មែរមានច្រើនប្រភេទដូចជា ក្រមាសូត្រដែលភាគច្រើនមានធ្វើនៅខេត្តកណ្ដាល ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ក្រមាអំបោះជ្រលក់ពណ៌ត្រុំនៅខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ក៏ដូចជានៅខេត្តផ្សេងៗទៀតទូទាំងប្រទេសកម្ពុជាផងដែរ។

ម្យ៉ាងវិញទៀតមុខរបរតម្បាញក្រមាក៏បានជួយសិប្បករកម្ពុជា និងជំរុញសេដ្ឋកិច្ចជាតិគួរឱ្យកត់សម្គាល់ផងដែរ។ ក្រុមគុនល្បុក្កតោ បានយកក្រមាជាយុទ្ធគុនសម្គាល់កម្រិតសមត្ថភាពដូចជា ថ្នាក់ក្រមាមាសជាដើម ហើយបច្ចុប្បន្ន ក្រមាជាវត្ថុដែលបង្ហាញពីអត្តសញ្ញាណជាតិ។

---

[៣] ទស់ (ស. ស.) ទាញយកដោយតាំងសញ្ញាថារបស់ដែលគេចោលឬឥតម្ចាស់ : ភិក្ខុទស់សំពត់បង្សុកូល, ទស់បន្ទុង។

***. តើយើងត្រូវធ្វើយ៉ាងដូចម្ដេចទើប ប្រជាជនអាចប្រើប្រាស់ក្រមាបានទូលំទូលាយ?***

*ដើម្បីលើកទឹកចិត្តឱ្យមនុស្សខ្មែរប្រើប្រាស់ «ក្រមាខ្មែរ» ឱ្យបានកាន់តែច្រើន គួរតែមានវិធានការដូចខាងក្រោម៖*

*. បង្កើនការយល់ដឹងពីតម្លៃវប្បធម៌ តាមរយៈការរៀបចំពិព័រណ៍ឬកម្មវិធីផ្សព្វផ្សាយអំពីប្រវត្តិសាស្ត្រ អត្ថន័យ និងសារសំខាន់នៃក្រមាខ្មែរ។*

*. ផ្សព្វផ្សាយតាមបណ្ដាញសង្គម និងសារព័ត៌មាន ជាពិសេសតារា និងបុគ្គលដែលមានឥទ្ធិពល មានកេរ្តិ៍ឈ្មោះល្បីៗ ត្រូវជួយផ្សព្វផ្សាយ ដោយប្រើប្រាស់ក្រមាជាសម្លៀកបំពាក់ ឬបង់ក នៅក្នុងពេលបំពេញការងារ ឬសកម្មភាពប្រចាំថ្ងៃដែលយើងអាចប្រើបាន និងចេញផ្សាយជាវីដេអូឬរូបភាពដែលបង្ហាញពីភាពទាក់ទាញ និងភាពសមស្របនៃក្រមាខ្មែរ។*

*. បញ្ចូលមុខវិជ្ជាអំពីសម្លៀកបំពាក់ប្រពៃណី ជាពិសេសក្រមា នៅក្នុងផ្នែកណាមួយនៃការសិក្សាអប់រំ។*

*. បង្កើតនិងលើកស្ទួយម៉ូដថ្មីៗ ដែលជាជម្រើសរចនាបថសម័យទំនើប ដើម្បីសមស្របនឹងជីវិតប្រចាំថ្ងៃ ដោយជំរុញឱ្យអ្នករចនាសម្លៀកបំពាក់បញ្ចូលក្រមាខ្មែរនៅក្នុងការរចនាដើម្បីប្រកួតប្រជែង។*

*. លើកស្ទួយសហគ្រិនក្នុងស្រុក និងផ្ដល់ជំនួយ ឬដំណើរការកម្ចីប្រាក់សម្រាប់អ្នកផលិតក្រមាខ្មែរ។*

*. បង្កើតទីផ្សារ ដើម្បីបង្ហាញនិងលក់ផលិតផលដែលធ្វើពីក្រមាខ្មែរ។*

*. រៀបចំជាព្រឹត្តិការណ៍ជាតិ "ថ្ងៃស្លៀកក្រមាខ្មែរ" ប្រចាំឆ្នាំ គឺអាចកំណត់យកថ្ងៃដែលយើងបានបញ្ចូលក្រមាដោយជោគជ័យជាបេតិកភ័ណ្ឌពិភពលោក គឺថ្ងៃទី៤ធ្នូ ដើម្បីជាការលើកស្ទួយផងនិងជាការចងចាំនូវថ្ងៃពិសេសនោះផងដែរ ។*

*វិធានការទាំងនេះគឺនឹងអាចបង្កើនទំនាក់ទំនងអារម្មណ៍ និងអត្តសញ្ញាណជាតិនៅក្នុងដួងចិត្តប្រជាពលរដ្ឋ ជាពិសេសចំពោះយុវជនខ្មែរយើង។*

*គួររំលឹកផងដែរថា កាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៨ ក្រមាដែលមានប្រវែងជាង ១០០០ម៉ែត្រ ដែលបានជាប់កំណត់ត្រាពិភពលោក* (Guinness World Records) *ដែលកម្មវិធីបំបែកកំណត់ត្រានេះ ត្រូវបានរៀបចំដោយក្រុមការងារ* GOGO Cambodia

ដោយមានការចូលរួមគ្នាញពីពលរដ្ឋរាប់ពាន់នាក់ក្នុងរយៈពេលជាង៥ខែនៅទីតាំងវាលព្រះមេរុ គឺស្ថិតនៅជាការចងចាំគួរជាទីមោទននៃកម្ពុជា ទន្ទឹមនឹងក្រមាបានក្លាយជាសម្បត្តិវប្បធម៌ទី៧របស់ខ្មែរ ដែលត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ(Intangible Cultural Heritage) បន្ទាប់ពី**របាំព្រះរាជទ្រព្យ**(ឆ្នាំ២០០៣) **ល្ខោនស្រមោលស្បែកធំ** (ឆ្នាំ២០០៥) **ល្បែងទាញព្រ័ត្រ** (ឆ្នាំ២០១៥) **ចាប៉ីដងវែង** (ឆ្នាំ២០១៦) **ល្ខោនខោលវត្តស្វាយ អណ្ដែត**(ឆ្នាំ២០១៨) និង**គុនល្បុក្កតោ**(ឆ្នាំ២០២២)។រីឯ**សម្បត្តិវប្បធម៌ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក** (World Heritage Sites) រួមមាន **រមណីយដ្ឋានអង្គរ**(ឆ្នាំ១៩៩២) **តំបន់ប្រាសាទព្រះវិហារ**(ឆ្នាំ២០០៨) **តំបន់ប្រាសាទសំបូរព្រៃគុក**(ឆ្នាំ២០១៧) **តំបន់ប្រាសាទកោះកេរ**(ឆ្នាំ២០២៣) ខណៈ**បណ្ណាសារឧក្រិដ្ឋកម្ម ប្រល័យពូជសាសន៍ទួលស្លែង**(ឆ្នាំ២០០៩) **ឯកសារសំឡេងនិទានរឿងរាមកេរ្តិ៍ ដោយតាគ្រុឌ**(ឆ្នាំ២០១៤) និង**រឿងអ៊ីណាវបុស្បា**(ឆ្នាំ២០១៧) ត្រូវបានចុះក្នុងបញ្ជីស្មារតីចងចាំនៃពិភពលោក។

**តើក្រមាបានផ្ដល់ការអប់រំ ឬទស្សនវិជ្ជាអប់រំដូចម្ដេចខ្លះដល់សង្គមមនុស្ស?**

ក្រមាខ្មែរ មិនមែនត្រឹមតែជាសម្បត្តិបែបរូបវន្តទេ ប៉ុន្តែវាជាសញ្ញាដ៏សំខាន់មួយនៃស្មារតី វប្បធម៌និងអត្តសញ្ញាណជាតិខ្មែរ។ នៅក្នុងបរិបទអប់រំ ក្រមាខ្មែរអាចបកស្រាយថាជាឧបករណ៍បង្រៀន និងបណ្ដុះបណ្ដាលផ្នែកទស្សនវិជ្ជាអប់រំ ដូចជា៖

. **ការអប់រំអំពីអត្តសញ្ញាណជាតិនិងភាពជាខ្មែរ** : ក្រមាខ្មែរជារូបវន្តមួយនៃភាពជាខ្មែរ។ ការប្រើប្រាស់និងការទទួលស្គាល់តម្លៃរបស់វា បង្រៀនឱ្យយុវជនស្គាល់ពីប្រភពកំណើតខ្លួន និងមានស្មារតីថែរក្សាអត្តសញ្ញាណជាតិ។ នេះជាគំនិតមួយនៃទស្សនវិជ្ជាអប់រំដែលផ្ដោតលើការបណ្ដុះបណ្ដាលមនុស្សឱ្យស្គាល់គុណតម្លៃនៃជាតិឯកត្តភាព និងសមត្ថភាពជាមនុស្សពេញលេញ។

. **ការអប់រំសីលធម៌ និងការរស់នៅ** ការប្រើក្រមា (ជាពិសេសក្នុងទំនាក់ទំនងសង្គមឬការជួយគ្នា) បង្ហាញពីគុណធម៌បង្ហាញនូវភាពសាមញ្ញ សុភាពរាបសារ ការគោរពគ្នា និងកិច្ចសហការជាសហគមន៍ដែលទស្សនវិជ្ជាអប់រំនេះ ផ្ដោតលើការ

បណ្តុះបណ្តាលមនុស្សឱ្យរស់នៅជាមួយគ្នា ដោយចេះគោរពនិងឱ្យតម្លៃគ្នាដែលជាប្រកតនៃភាពរស់នៅក្នុងសន្តិភាព រស់នៅក្នុងភាពសុខដុម មានការយោគយល់អធ្យាស្រ័យ និងមានមនុស្សធម៌។

. ***ការអប់រំអំពីការច្នៃប្រឌិត និងការប្រើប្រាស់ធនធានក្នុងជីវិតប្រចាំថ្ងៃ*** : ក្រមាខ្មែរត្រូវបានបំពាក់ដោយចំណេះដឹងតាមរយៈបុព្វបុរសជំនាន់មុន បន្សល់ទុកដល់ខ្មែរជំនាន់ក្រោយ ដែលអាចច្នៃក្រមាប្រើប្រាស់បានស្ទើគ្រប់បែបយ៉ាង ដូចជា ការផ្លាស់ផ្លូតទឹក ជាអង្រឹងក្មេង ជាឈ្នួតក្បាល និងប្រើប្រាស់ផ្សេងៗទៀតតាមតម្រូវការជាច្រើន។ ក្រមាបានបង្ហាញពីការបង្រៀនឱ្យគិតច្នៃប្រឌិតក្នុងការប្រើធនធានដែលមិនប៉ះពាល់ដល់បរិស្ថានដែលជាគំនិតសំខាន់មួយក្នុងការអប់រំពេលបច្ចុប្បន្ន។

. ***ការអប់រំអំពីសិល្បៈ និងអារម្មណ៍*** ក្រមាខ្មែរមានលក្ខណៈស្រស់ស្អាត ទាំងក្នុងរចនាប័ទ្មនិងពណ៌ផ្សេងៗ។ វាស្វែងរកភាពសមស្របរវាងការអនុវត្តនិងសោភ័ណភាព។ ទស្សនវិជ្ជាអប់រំនេះលើកស្ទួយឱ្យមនុស្សមានការយល់ដឹង និងកត់សម្គាល់ពីសិល្បៈក្នុងជីវិតប្រចាំថ្ងៃ។

. ***ការអប់រំអំពីភាពជាមនុស្សពេញលេញ ដោយការស្គាល់ ការរក្សា និងការប្រើប្រាស់ក្រមា*** : គឺជាផ្នែកមួយនៃការអភិវឌ្ឍជីវិតជាក់ស្តែងក្នុងទំនាក់ទំនងនឹងបុគ្គលិកលក្ខណៈសង្គម និងវប្បធម៌។ វាបង្ហាញថា ការអប់រំមិនមែនមានតែការសិក្សា លិខិតឬវិជ្ជាជីវៈទេ ប៉ុន្តែសំខាន់នៅក្នុងការបណ្តុះបណ្តាលស្មារតី សីលធម៌ វប្បធម៌ ក៏ដូចជាចក្ខុវិស័យនៃជីវិត។

សរុបមក ក្រមាខ្មែរផ្តល់នូវទស្សនវិជ្ជាអប់រំដែលពង្រឹងអត្តសញ្ញាណជាតិ សីលធម៌ សិល្បៈ កិច្ចសហការសង្គម និងភាពច្នៃប្រឌិត។ វាជាមេរៀនជ្រៀនអំពីជីវិតមួយតាមរយៈវត្ថុវប្បធម៌ និងអាចនិយាយម៉្យាងទៀតថា ក្រមាខ្មែរជាសម្បត្តិវប្បធម៌សំខាន់មួយដែលមានតម្លៃខ្ពស់ក្នុងសង្គមខ្មែរ វាមានមុខងារជាច្រើនដែលអាចយកមកពិចារណាថា វាបង្ហាញពីទស្សនវិជ្ជាអប់រំដែលស្ថិតនៅក្នុងវប្បធម៌ខ្មែរដូចខាងក្រោម៖

. ការចេះអភិរក្ស និងចេះគោរពប្រពៃណីវប្បធម៌ខ្មែរ។ ការប្រាស់ប្រើក្រមាខ្មែរជារៀងរាល់ថ្ងៃបង្ហាញថា មានគំនិតថែរក្សាវប្បធម៌ខ្លួន។

. ការអប់រំអំពីសិល្បៈ និងអារម្មណ៍ គឺក្រមាខ្មែរមានសោភ័ណភាពខ្ពស់ ក្នុងការចាក់សម្លៀកបំពាក់ និងការតុបតែង ដែលនេះជាផ្នែកមួយនៃការអប់រំឱ្យមានចំណេះដឹងអំពីសិល្បៈ ស្រឡាញ់សិល្បៈ និងដឹងចេះមើលឃើញអត្ថន័យក្នុងសោភ័ណភាព។

. ការអប់រំអំពីអត្តសញ្ញាណជាតិនិងស្មារតីសហគមន៍។ ក្រមាខ្មែរដូចជាសញ្ញាបញ្ជាក់អត្តសញ្ញាណជាតិខ្មែរ។ វាបានបង្រៀនឱ្យស្គាល់តម្លៃ និងអប់រំឱ្យមានមោទនភាពក្នុងការប្រើក្រមា ជាសារៈសំខាន់ក្នុងការបណ្ដុះបណ្ដាលស្មារតីជាតិ និងស្មារតីសហគមន៍។

. ការអប់រំអំពីកិច្ចសហការនិងចំណេះដឹងប្រើប្រាស់ធនធានក្នុងជីវិតប្រចាំថ្ងៃ។ ក្រមាខ្មែរត្រូវបានប្រើប្រាស់ជាប្រដាប់ប្រើប្រាស់ជាច្រើន ដែលបង្ហាញពីការអប់រំឱ្យមនុស្សស្គាល់ពីភាពច្នៃប្រឌិត និងវិធីប្រើប្រាស់ធនធានដោយអត្ថប្រយោជន៍ខ្ពស់។

ដូច្នេះក្រមាខ្មែរមិនមែនត្រឹមជាវត្ថុសិល្បៈបុរាណទេ ប៉ុន្តែវាបង្រៀនគុណតម្លៃជំនឿ សិល្បៈ អត្តសញ្ញាណ ក៏ដូចជាការច្នៃប្រឌិត ដែលធ្វើឱ្យក្រមាខ្មែរក្លាយជាគ្រឿងសំខាន់មួយក្នុងទស្សនវិជ្ជាអប់រំខ្មែរ។

. សូមឱ្យមានស្មារតីជាតិនិយមស្រឡាញ់អត្តសញ្ញាណក្រមា ដោយមិនបំភ្លេចជាតុដើម ជាពិសេសសូមឱ្យពុកម៉ែបងប្អូនបន្តថែរក្សា ផលិត និងប្រើប្រាស់ក្រមាក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដែលជាអត្តសញ្ញាណរបស់ជាតិ និងជាកេរដំណែលប្រពៃណីដ៏ថ្លៃថ្លាក្នុងសង្គមកម្ពុជា តាំងពីដើមរៀងមក។



. រួមគ្នាក្នុងការថែរក្សា ការពារ និងលើកតម្កើងគុណតម្លៃ "ក្រមា" ទុកជាកេរមរតកសម្រាប់មនុស្សជាតិជំនាន់ក្រោយតរៀងទៅ កុំឱ្យបាត់បង់ ដ្បិត "ក្រមា" គឺជាផ្នែកមួយដ៏សំខាន់ក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជាចាប់តាំងពីពេលកើតរហូតដល់ពេលស្លាប់ ដោយប្រជាជននិយមប្រើប្រាស់តាមតម្រូវការផ្សេងៗ ជាភួយគ្រប ដណ្ដប់ខ្លួន ជាការតុបតែងលម្អដោយច្នៃជាសម្លៀកបំពាក់គ្រប់ទម្រង់ ជាមួកបាំង

កម្តៅព្រះអាទិត្យ ជាអង្រឹងក្មេង ជាកន្សែង សម្រាប់ជូតខ្លួន និងប្រើប្រាស់ក្នុងពិធីផ្សេងៗ ទៅតាមប្រពៃណីសាសនាជាដើម។



. សូមឱ្យក្រមាខ្មែរស្ថិតនៅក្នុងក្រអៅបេះដូង ស្ថិតនៅក្នុងការចងចាំ និងប្រើប្រាស់ជាបន្តដរាបរៀងទៅ តាមរយៈការផ្តល់នូវគុណតម្លៃអស្ចារ្យ នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៤ ដែល«ក្រមា»របស់ប្រទេសកម្ពុជា ត្រូវបាន ដាក់បញ្ចូលទៅក្នុងបញ្ជីតំណាងបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់



សម្ភារៈប្រើប្រាស់ផលិតពីក្រមា

អង្គការយូណេស្កូ (UNESCO) នៅទីក្រុងអាសង់ស្យុង សាធារណរដ្ឋប៉ារ៉ាហ្គាយ។

## ឯកសារពិគ្រោះ


. ជួន ណាត **វចនានុក្រមខ្មែរ**

. https://thmeythmey.com/detail/142597 ៧ ធ្នូ ២០២៤

. ភ្នំពេញ ប៉ុស្តិ៍ | ក្រមាខ្មែរត្រូវបានដាក់ចូលក្នុងបញ្ជីតំណាងបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ

. អង្គការយូណេស្កូប្រចាំកម្ពុជា អបអរសាទរ «ក្រមាខ្មែរ» ដែលបានចុះបញ្ជីចូលក្នុងបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ - Khmernote

. ប្រជាជាតិកម្ពុជា ត្រៀមអបអរចំពោះការដាក់បញ្ចូល «ក្រមាខ្មែរ» ជាសម្បត្តិបេតិកភណ្ឌអរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ - Troryorng Media

. ក្រមាគឺជាស្នាដៃសិប្បកម្មត្បាញដែលដូនតាខ្មែរ បានបន្សល់ទុកសម្រាប់ជាកេរ្តិ៍តំណែលតកូនចៅជាច្រើនជំនាន់មកហើយ – វិមាន៧មករា

. «ក្រមាខ្មែរ»ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីតំណាងនៃបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ - ស៊ីស៊ីថាមស៍

. សម្ដេចតេជោ ហ៊ុន សែន៖ ក្រមាខ្មែរ ដែល
ត្រូវបានចុះបញ្ជីតំណាង នៃបេតិកភណ្ឌវប្ប
ធម៌ អរូបីនៃមនុស្សជាតិ របស់អង្គការយូ
ណេស្កូ ជាមោទនភាពថ្មីមួយទៀតរបស់កម្ពុ
ជា - ក្រសួងព័ត៌មាន
. «ក្រមាខ្មែរ»ត្រូវបានដាក់បញ្ចូលក្នុងបញ្ជី
តំណាងនៃបេតិកភណ្ឌវប្បធម៌អរូបីនៃ
មនុស្សជាតិ - ស៊ីស៊ីថាមស៍